ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការព្រហ្មទណ្ឌ

# សាលក្រម

**សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៣៤ អ.ក**

ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១

**សំណុំរឿងស៊ើបសួរលេខ ៩៦៦ ស.ស**

ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១

**សំណុំរឿងជំនុំជម្រះលេខ ១៥៥ ជ.រ**

ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២

**សាលក្រមព្រហ្មទណ្ឌលេខ ៩៥ ប**

ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ០៩ ព្រឹក។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ១០ នាទីព្រឹក។

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

### ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

ឈ្មោះ [redacted] **ណាង** ភេទប្រុស កើតឆ្នាំ ១៩៧៤ (អាយុ ៤៧ ឆ្នាំ) ជនជាតិខ្មែរ មុខរបរ កសិករ។

ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] **ស៊ើម** (រ) ម្ដាយឈ្មោះ [redacted] **ម៉ិច** (រ) ប្រពន្ធឈ្មោះ [redacted] **រិន** មានកូន ០៦ នាក់។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។



Scanned with CamScanner

ត្រូវជាប់ចោទពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្ត នៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើស ព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ ប្រតិភូគណៈមេធាវីប្រចាំខេត្តកណ្តាល។

**ខ. អំពីអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] **ផន** ភេទប្រុស អាយុ ៤២ ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ។

ទីលំនៅភូមិអណ្តូង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល។

**សំណុំរឿងព្រហ្មទណ្ឌបញ្ជូនមកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២៨ ដកជស/២២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមាន៖**

**អង្គហេតុដែលឡើងមកតុលាការ**

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ៣០ នាទី មានករណី **ហិង្សាប្រព្រឹត្តដោយសហព័ទ្ធ** កើតឡើងនៅភូមិគោកអណ្តែត ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល បង្កឡើងដោយឈ្មោះ [redacted] **ណាង** ត្រឡប់មកពីផឹកស្រាជាមួយបងប្អូនមកដល់ផ្ទះវិញបានខឹងជនរងគ្រោះឈ្មោះ [redacted] **រិន** ភេទស្រី អាយុ ៤៤ ឆ្នាំ ដែលត្រូវជាប្រពន្ធដោយចោទថា ប្រពន្ធមានសាហាយ ក៏បានយកឈើជ្រុងមួយដើមប្រវែង ៨៨ ស.ម ទំហំមុខកាត់ ១១ ស.ម វាយចំពីលើក្បាលរបស់ជនរងគ្រោះចំនួន ០២ ដងបណ្តាលឱ្យបែកក្បាលហូរឈាម និងស្លាប់បាត់ស្មារតីតែម្តង។ បន្ទាប់ពីទទួលពាក្យបណ្តឹងពីក្រុមគ្រួសារជនរងគ្រោះ សមត្ថកិច្ចបានចុះឃាត់ខ្លួនឈ្មោះ [redacted] **ណាង** រួមទាំងវត្ថុតាងបញ្ជូនមកអធិការដ្ឋានស្រុកស្អាងដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។ កន្លងមកឈ្មោះ [redacted] **ណាង** តែងតែរករឿងប្រពន្ធ និងវាយធ្វើបាបប្រពន្ធជាញឹកញាប់ រាល់ពេលដែលផឹកស្រាស្រវឹង ហើយក៏ធ្លាប់បានសមត្ថកិច្ចធ្វើការអប់រំ និងធ្វើកិច្ចសន្យារួចមកហើយដែរ។

**អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី**

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី**

អំពីវិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន ។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន ។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី**

**១. ការសួរចម្លើយជនជាប់ចោទ**

១.១. ជនជាប់ចោទឈ្មោះ [redacted]**ណាង**៖ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ ខ្លួនទៅផ្ទះប្អូនហូបស្រាបៀរ ៣ កំប៉ុង ក្រោយមករួចខ្លួន ក៏ត្រឡប់មកផ្ទះវិញ ពេលនោះក៏បាត់ប្រពន្ធ ពេលប្រពន្ធមកវិញខ្លួនក៏សួរថា "ទើបមកពីណា ប្រពន្ធឆ្លើយថាមកពីណាស្រេចតែអញ" ពេលនោះខ្លួនក៏សុំលុយប្រពន្ធ ១០០០ (មួយពាន់) រៀល ទិញបារី

ជក់ ពេលនោះប្រពន្ធថា "បើមិនធ្វើចិត្តត្រជាក់ដាក់ខ្លួនលែងនៅជាមួយហើយ" ពេលនោះខ្លួនខឹងក៏យកឈើជ្រុងវាយទៅលើក្បាលរបស់ប្រពន្ធ ដោយវាយពីក្រោយប្រពន្ធ ដោយវាយចំនួន ០២ (ពីរ) ឈើ បណ្តាលឱ្យត្រូវរបួសត្រង់កន្លែងណាក៏ខ្លួនមិនដឹងដែរ។ ក្រោយវាយរួចប្រពន្ធខ្លួនធ្លាក់ពីលើគ្រែ ត្រូវចំជណ្តើរប្រអប់ផ្ទះ។ ពេលនោះខ្លួនមិនបានលើគ្រាប្រពន្ធនោះទេ ខ្លួនជិះម៉ូតូមកកន្លែងប៉ុស្តិ៍ប៉ូលីសតែម្តង។ មូលហេតុខ្លួនវាយប្រពន្ធ ដោយសារខឹងប្រពន្ធខ្លាំងពេក តែមិនមានចេតនាបណ្តាលឱ្យប្រពន្ធស្លាប់នោះទេ។ ខ្លួនគ្រាន់តែមានកំហឹងខ្លាំងទើបវាយប្រពន្ធបែបនេះ។ ខ្លួនរស់នៅជាមួយប្រពន្ធជាង ២០ (ម្ភៃ) ឆ្នាំមកហើយ ហើយកន្លងមកខ្លួនក៏មិនធ្លាប់វាយប្រពន្ធដែរទើបតែវាយលើកទី១ ប៉ុណ្ណោះ។ ប្រពន្ធខ្លួនឈ្មោះ[redacted]ន័យ។ ខ្លួនវាយប្រពន្ធរបស់ខ្លួនតែ ២ ដំបងនោះទេ ហើយពេលវាយនោះប្រពន្ធរបស់ខ្លួនកំពុងតែអង្គុយលើគ្រែ ហើយខ្លួនក៏វាយពីក្រោយខ្នង ហើយប្រពន្ធគាត់ច្រត់ដៃខុសបណ្តាលឱ្យធ្លាក់ពីលើគ្រែ តែពេលនោះខ្លួនវាយតែ ២ ដំបងប៉ុណ្ណោះ។ ដំបងទំហំប៉ុនកដៃ ឈើជ្រុងប្រវែងកន្លះម៉ែត្រ ជាឈើដែលសៀតនៅក្រោមផ្ទះ។ ខ្លួនវាយប្រពន្ធ ដោយសារខ្លួនខឹងនឹងប្រពន្ធដេញខ្លួនចេញពីផ្ទះ។ ខ្លួនមានអារម្មណ៍សោកស្តាយ និងកែប្រែខ្លួនករណីតុលាការសម្រាលទោស។ ចំពោះរូបថតដែលបង្ហាញ ខ្លួនពិតជាបានយកដំបងវាយប្រពន្ធមែន ដោយសារឈរកៀកប្រពន្ធតែប៉ុណ្ណោះ។ ខ្លួនពិតជាមិនមានចេតនាក្នុងការសម្លាប់ប្រពន្ធនោះទេ។ ពេលវាយរួចខ្លួនក៏មិនបានពិនិត្យមើលមុខរបស់ប្រពន្ធដែរ។ ចំពោះរូបថតដែលចៅក្រមបង្ហាញគឺពិជាប្រពន្ធរបស់ខ្លួនមែន។ ពីមុនខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀន។

**២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

២.២. អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផន៖** កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៤ ល្ងាច ខ្លួនកំពុងតែកាយទ្រនប់ចិញ្ចឹមត្រីនៅក្រោយផ្ទះ ស្រាប់តែក្មួយប្រុសខលមកប្រាប់ថា ប៉ារបស់ខ្លួនវាយម៉ាក់ខ្លួន បែកក្បាលហើយ ហើយខ្លួនប្រាប់ឱ្យក្មួយឆាប់ដឹកម្តាយទៅមន្ទីរពេទ្យទៅ ពេលនោះខ្លួនប្រញាប់ទៅកន្លែងកើតហេតុខណៈពេលជិតទៅដល់ភូមិ ត្រូវអ្នកភូមិប្រាប់ថា ឈ្មោះ[redacted] ណាង រត់បាត់ហើយ ភ្លាមនោះក៏ខ្លួនខលទៅប៉ូលីសក្រាំងយ៉ូវឱ្យជួយអន្តរាគមន៍ រួចប៉ូលីសក្រាំងយ៉ូវបោះដៃមកប៉ូលីសស្អាងភ្នំឱ្យជួយអន្តរាគមន៍វិញ បន្ទាបមកខ្លួនប្រញាប់ទៅមើលអ្នកជំងឺនៅពេទ្យដែលជាបងបង្កើតរបស់ខ្លួន ពេលទៅដល់មន្ទីរពេទ្យ ឃើញបងស្រីឈ្មោះ [redacted] រិន ហៅ នៃ មានរបួសលើផ្ទៃមុខទាំងសងខាង និងក្បាលជាទម្ងន់។ ក្រោយមក ប្អូនប្រុសបង្កើតរបស់ខ្លួនឈ្មោះ [redacted]ភឿន ទូរស័ព្ទប្រាប់ខ្លួនថា ប៉ូលីសស្អាងភ្នំចាប់ឈ្មោះ[redacted]ណាង បានហើយ។ រហូតមកដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយបងខ្លួនមានរបួសធ្ងន់ហើយក្មួយស្រីខ្លួនរវល់មើលថែម្តាយនៅមន្ទីរពេទ្យពុំមាននរណាមកប្តឹងទើបខ្លួនមកដាក់ពាក្យបណ្តឹងជំនួសតែម្តង។

**៣. ការស្តាប់ចម្លើយសាក្សី**

៣.១. សាក្សីឈ្មោះ[redacted]**ចន៖** នៅថ្ងៃកើតហេតុ ខ្លួនគេងថ្ងៃនៅផ្ទះរបស់ខ្លួន ស្រាប់តែក្មួយប្រុសរបស់ខ្លួនរត់មកប្រាប់ខ្លួនថា "ពូៗប៉ារបស់ក្មួយបានវាយម្តាយរបស់ខ្លួន"។ ពេលខ្លួនទៅដល់ផ្ទះរបស់ជនរងគ្រោះ គឺមានគ្នាច្រើន ដោយពេលទៅដល់ បានឃើញជនរងគ្រោះនៅលើដីបាត់ហើយ តែលោកឈ្មោះ[redacted] ណាង នៅកន្លែងកើតហេតុដែរ។ ជនរងគ្រោះបញ្ជូនទៅពេទ្យព្រែកតូច។ ខ្លួនត្រូវជាប្អូនថ្លៃរបស់ជនរងគ្រោះ ។ ក្រោយពេលគេង



Scanned with CamScanner

ពេទ្យបានមួយសប្តាហ៍ ឬរយៈពេលណា គឺខ្លួនមិនចាំនោះទេ។ ខ្លួនគ្រាន់តែដឹងថា ក្រោយកើតហេតុមួយរយៈ។ កន្លងមកពីនាក់ប្តីប្រពន្ធគាត់ខ្លួនមិនដឹងថា មានទំនាស់ញឹកញាប់ ឬយ៉ាងនោះទេ។

**សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផន** ៖ អវត្តមាន។

២. ជនជាប់ចោទឈ្មោះ [redacted] **ណាង** ៖ ខ្លួនពុំមានសំណូមពរអ្វីនោះទេ។

**ខ. សេចក្តីសន្និដ្ឋាន៖**

**១. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ក្រោយពីបានស្តាប់ការសាកសួរ ដេញដោលពីជនជាប់ចោទ និងសាក្សី តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីការសន្និដ្ឋានស្ថាពរដដែល។ ហេតុស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់។

**២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

ក្រោយពីបានសិក្សាពីសំណុំរឿង ការសាកសួរ ឃើញថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទី១ បាត់ធាតុផ្សំនៃបទល្មើស គឺធាតុអត្តនោម័ត គឺមិនមានចេតនាក្នុងការសម្លាប់ជនរងគ្រោះជាប្រពន្ធឡើយ ដោយអចេតនាតាំងពីដំបូង គឺស្នើប្តូរមាត្រា ២២៤ មកមាត្រា ២២២ គឺជនជាប់ចោទមានកូនក្នុងបន្ទុកទាំង ៦ នាក់ ហេតុនេះប្រពន្ធស្លាប់បាត់ទៅហើយ ហើយតាមរយៈគោលនយោបាយកាត់បន្ថយភាពក្រីក្រ ហេតុនេះស្នើសុំកែប្រែពីមាត្រា ២២៤ មកមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ។

**គ. ការឆ្លើយតបរបស់៖**

**១. តំណាងអយ្យការ៖**

ការស្នើសុំរបស់មេធាវី គឺមិនសមស្រប ដែលថាខ្វះធាតុផ្សំអត្តនោម័ត គឺមិនមានហេតុផលសមស្របនោះឡើយ ដោយហេតុថាជនរងគ្រោះបានស្លាប់បាត់ហើយ ដែលរឿងនេះកើតឡើងគឺជនជាប់ចោទស្រវឹង ទើបវាយប្រពន្ធ។ ហេតុនេះការលើកឡើងថា តំណាងអយ្យការចោទខ្វះធាតុផ្សំ គឺមិនអាចទទួលយកបាន។ ករណីកើតឡើងពីបញ្ហាកូន និងគោលនយោបាយ គឺនៅតែមិនអាចទទួលយកបានឡើយ។

*- ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១៨៣៤ អ.ក** ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ណាង** ភេទប្រុស កើតឆ្នាំ ១៩៧៤ (អាយុ ៤៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅភូមិគោកអណ្តែត ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១



Scanned with CamScanner

បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] ណាង៕

**គ. អំពី ពិរុទ្ធភាព**

១. តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់សាក្សី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៅតំណាងអយ្យការ នៅចំពោះមុខចៅក្រមស៊ើបសួរ និងនៅក្នុងកិច្ចពិភាក្សាដេញដោល រួមទាំងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងភស្តុតាងផ្សេងបង្ហាញថា អង្គហេតុដែលប្តឹងមកតុលាការពិតជា កើតឡើងយ៉ាងពិតប្រាកដ។ ហេតុនេះការណ៍ដែលអង្គហេតុដែលប្តឹងមកតុលាការត្រូវទទួលស្គាល់អង្គហេតុដែលប្តឹងមកតុលាការ តុលាការនឹងបន្តការពិនិត្យវាយតម្លៃ និងផ្ទៀងផ្ទាត់រវាងអង្គហេតុ និងបទចោទប្រកាន់ដែលមានលើជនជាប់ចោទ។

២. តាមសំអាងហេតុចំណុចទី ១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ណាង បានបំពេញធាតុសត្យានុម័តនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទឆ្លើយសារភាពថា ខ្លួនពិតជាបានយកដំបងឈើវាយប្រពន្ធចំនួន ០២ ដំបង បណ្តាលឱ្យធ្លាក់ពីលើគ្រែត្រូវចំជណ្តើរប្រអប់ផ្ទះ ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចម្លើយសាក្សី និងភស្តុតាងជារូបថត។ ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការឃើញថា មានភាពត្រឹមត្រូវចំពោះធាតុផ្សំនៃបទល្មើស និងអង្គហេតុ ចំណែកសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឃើញថា ពុំត្រឹមត្រូវទេ ក្នុងការកំណត់បទល្មើសចំពោះអង្គហេតុដែលប្តឹងមកតុលាការថា ជាបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន** តាមមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ ដោយលើកឡើងអំពីភាពគ្មានចេតនាក្នុងការសម្លាប់របស់ជនជាប់ចោទចំពោះជនរងគ្រោះ។ ធាតុសត្យានុម័តនៃបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន** គឺជាការប្រើប្រាស់អំពើហិង្សា ដែលកើតចេញពីប្រធាននៃបទល្មើស គឺជាជនជាប់ចោទ ទៅលើជនរងគ្រោះដែលជាសហព័ទ្ធ ឬអនីតិសង្វាសជន ហើយពុំមានហេតុណាមួយបង្កឱ្យមានពិការភាព ឬមរណភាពនៃជនរងគ្រោះនោះទេ។ ចំណែកធាតុអត្តនោម័តនៃបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន** គឺជាការប្រើប្រាស់អំពើហិង្សាដោយចេតនា ដែលកើតចេញពីឆន្ទៈ ឬចំណង់របស់ជនជាប់ចោទ។ ចំពោះបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** តាមមាត្រា ២២៤ នៃ



Scanned with CamScanner

ក្រមព្រហ្មទណ្ឌ ឃើញថា ធាតុសត្យានុម័តនៃបទល្មើសនេះ គឺជាការប្រើប្រាស់អំពើហិង្សា ដែលកើតចេញពីប្រធាននៃបទល្មើស ជាជនជាប់ចោទ ទៅលើជនរងគ្រោះ ទោះជាសហព័ទ្ធ ឬអនីតិសង្វាសជន ឬតតិយជនផ្សេងក្តី ហើយជាលទ្ធផលនៃអំពើនេះ បានបណ្តាលមរណភាពនៃជនរងគ្រោះនោះទេ។ ចំណែកធាតុអត្តនោម័ត គឺការប្រើប្រាស់អំពើហិង្សាដោយចេតនា ដែលកើតចេញពីឆន្ទៈ ឬចំណង់របស់ជនជាប់ចោទ ប៉ុន្តែគ្មានចេតនាសម្លាប់ជនរងគ្រោះ។ ផ្ទុយទៅវិញ បើសិនជាមានចេតនាក្នុងសម្លាប់វិញ វាគឺជាបទ ឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ឬបទ ឃាតកម្មគិតទុកជាមុន តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ទៅវិញទេ។ហេតុនេះ អ្វីដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសេចក្តីសន្និដ្ឋាន គឺជាសន្និដ្ឋានដោយពុំបានពិនិត្យអំពីធាតុផ្សំនៃបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន** តាមមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ និងធាតុផ្សំនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ក្នុងមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ។

៣. តាមសំអាងហេតុចំណុចទី ១ ដល់ទី២ នៃចំណុច គ (ពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ណាង** បានបំពេញធាតុអត្តនោម័តនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ព្រោះជនជាប់ចោទបានដឹងនូវអំពើរបស់ខ្លួនថាជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន។

**៤.** តាមសំអាងហេតុចំណុចទី២ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ណាង** បានបំពេញធាតុផ្សំនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **ណាង** បានបំពេញធាតុផ្សំនៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទ



Scanned with CamScanner

ឈ្មោះ [redacted] ណាង មានពិរុទ្ធភាពពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

ផ្អែកតាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាន និងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស និងដោយ តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារ តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **ណាង ចំនួន ១០ (ដប់) ឆ្នាំ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ព្រោះអំពើរបស់ជនជាប់ចោទបានប្រព្រឹត្តឡើងក្នុងសភាពឃោរឃៅព្រៃផ្សៃចំពោះជនរងគ្រោះ ហើយពុំបានធ្វើការសង្គ្រោះជនរងគ្រោះភ្លាមៗ ក្រោយពេលដែលជនជាប់ចោទបានធ្វើការវាយទៅលើជនរងគ្រោះរួច។ ត្បិតជនជាប់ចោទគ្មានចេតនាក្នុងការសម្លាប់ក៏ដោយចុះ ប៉ុន្តែជនជាប់ចោទបានដឹងច្បាស់ណាស់ថា ការវាយផ្នែកក្រោយនៃផ្នែកក្បាល នឹងបង្កលទ្ធភាពខ្ពស់ក្នុងការស្លាប់៕

**ឆ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

**ជ. អំពី វត្ថុចាប់យក**

វត្ថុចាប់យកដែលរួមមាន **ឈើជ្រុងចំនួន ០១ ដើម មានប្រវែង ៨៨ ស.ម ទំហំមុខកាត់ ១១ ស.ម** ដែលត្រូវបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] **ណាង** ជាវត្ថុដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ហេតុដូច្នេះ តុលាការនឹងសម្រេចរឹបអូសវត្ថុចាប់យកនេះ។

**ឈ. អំពី បណ្តឹងរដ្ឋប្បវេណី**

១. ដោយហេតុថា ជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] **ណាង** ត្រូវបានរកឃើញថា មានពិរុទ្ធភាពលើអង្គហេតុដែលបានប្តឹងមកតុលាការ ហេតុដូច្នេះ តុលាការនឹងសម្រេចពិចារណាអំពីសំណងនៃការខូចខាត និងសំណងជំងឺចិត្ត ប្រសិនបើមានការទាមទារ។



Scanned with CamScanner

២. ផ្អែកតាមភស្តុតាងដែលមានក្នុងសំណុំរឿងបង្ហាញថា ពុំមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នោះ ហេតុដូច្នេះ តុលាការនឹងមិនសម្រេចអំពីបណ្តឹងរដ្ឋប្បវេណីនោះទេ។

## សេចក្តីសម្រេច

១. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **ណាង** ភេទប្រុស កើតឆ្នាំ១៩៧៤ (អាយុ ៤៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ៕

២. ផ្តន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **ណាង** ភេទប្រុស កើតឆ្នាំ១៩៧៤ (អាយុ ៤៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ **ចំនួន ១០ (ដប់) ឆ្នាំ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិគោកអណ្តែត ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ៕

៣. វត្ថុចាប់យកដែលរួមមាន **ឈើជ្រុងចំនួន ០១ ដើម មានប្រវែង ៨៨ ស.ម ទំហំមុខកាត់ ១១ ស.ម ត្រូវ** រឹបអូស។

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈនៅចំពោះមុខជនជាប់ចោទ។*

***សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈនៅថ្ងៃ សុក្រ ០៣ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១០ និង ០០ នាទីព្រឹក នៅសាលសវនាការលេខ ០១។***

*ភាគីដែលមានបំណងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើតាមការកំណត់របស់ច្បាប់។*

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

**ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ០៣ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner